# គំនូរមារព័ន្ធ

## ១- ព័ត៌មានទូទៅ

ការគោរពប្រតិបត្តិព្រះពុទ្ធសាសនាថេរវាទនៅប្រទេសកម្ពុជា ក្រៅពីបានទទួលឥទ្ធិពលក្នុងផ្នែកជំនឿ ផ្នត់គំនិត ទស្សនៈវិជ្ជា គម្ពីរ ក្បួនខ្នាត ទម្រង់សិល្បៈ ជាច្រើនប្រភេទតាមរយៈគម្ពីរជាតកផ្សេងៗមានៈ គម្ពីរពុទ្ធវង្ស គម្ពីរទីបវង្ស គម្ពីរមហាវង្ស គម្ពីរទសជាតក គម្ពីរបញ្ញាសជាតក និងគម្ពីរបឋមសម្ពោធិជាដើម។ បណ្តាគម្ពីររឿងសាសនាទាំងអស់នោះសុទ្ធសឹងតែបានពោលរៀបរាប់អំពីសាវតារព្រះពុទ្ធជាម្ចាស់កាលមិនទាន់បានត្រាស់ ក្នុងជាតិដែលបានត្រាស់ និងតំណសាសនារុងរឿង ធ្លាក់ចុះរហូតដល់ព្រះពុទ្ធសាសនាផ្សាយនៅកោះលង្កា។ ដំណើររឿងក្នុងគម្ពីរខាងលើនេះ យើងសង្កេតឃើញថាគេតែងនិយមស្រង់យកកណ្តាណាមួយនៃរឿងមកស្តែងចេញជាសិល្បៈគំនូរនៅតាមវត្តអារាមខ្មែរគឺនៅក្នុងសាលាឆាន់ ធម្មសភា និងព្រះវិហារដែលបង្ហាញពីដំណើរជីវិតព្រះពោធិសត្វប្រកបដោយលក្ខណៈអភិនីហារ អស្ចារ្យយ៉ាងក្រៃលែង។ ផ្ទាំងគំនូរទាំងនេះយើងអាចចែកជាពីរផ្នែកធំៗៈ

***ក.គំនូរទសជាតក៍ៈ*** គឺជាដំណើរពីជីវិតព្រះពោធិកំពុងបំពេញបារមីទាំង១០ក្នុងជាតិទាំង១០ខុសៗគ្នា។ ជាទូទៅគំនូរទសជាតក៍គេតែគូរនៅផ្នែកខាងក្រោមតាមចន្លោះទ្វារ និងបង្អួចរៀងគ្នាពីរឿងព្រះតេមិយជាជាតិទី១ រហូតដល់រឿងព្រះវេស្សន្តរជាជាតិទី១០។

***ខ.គំនូរបឋមសម្ពោធិ៍ៈ*** គំនូរប្រភេទនេះគេច្រើននិយមហៅថាគំនូរពុទ្ធប្បវត្តិ។ ករណីដែលយើងហៅថាគំនូរពុទ្ធប្បវត្តិព្រោះគំនូរតាមដំណើររឿងក្នុងគម្ពីរបឋមសម្ពោធិ ជាគម្ពីររឿងនិទានសាសនានិយាយរៀបរាប់ពីដំណើរជីវិតរបស់ព្រះពុទ្ធតាំងពីមង្គលការព្រះមាតាបិតាព្រះពុទ្ធរហូតទល់គ្នានឹងការវិនាសសាសនាក្នុងវស្សាទី៥០០០[១]។

ប៉ុន្តែទីតាំងគំនូរទាំងពីរប្រភេទនេះ មិនមានដំណើររឿងរៀងគ្នាតាមលំដាប់លំដោយដូចសេចក្តីបរិយាយក្នុងគម្ពីរ ព្រោះផ្ទៃគំនូរអាចខុសលំដាប់គ្នាហើយអត្ថន័យគំនូរក៏អាចប្រែប្រួលខុសប្លែកគ្នាទៅតាមសម័យកាល តាមរបត់សង្គម និងរបត់ប្រវត្តិសាស្ត្រ។ ហេតុផលទាំងអស់នេះហើយ

[១] គម្ពីរបឋមសម្ពោធិត្រង់សេចក្តីបញ្ចអន្តរធាន

បានជាគំនូរនៅតាមតំបន់នានាក្នុងប្រទេសកម្ពុជា ខុសប្លែកពីគ្នាសូម្បីរឿងដែលដកស្រង់ចេញពីប្រភពគម្ពីរតែមួយ ប៉ុន្តែដំណើររឿងខុសគ្នា ហើយការនិយមលើកយកសាច់រឿងតាមកណ្ឌក្នុងគម្ពីរក៏មិនបានចប់ចុងចប់ដើម។ ជាក់ស្តែងក្នុងគំនូរបឋមសម្ពោធិ៍ជាការអង្កេតទូទៅយើងឃើញថាមិនមានទីអារាមណាមួយដែលគូរគំនូរបឋមសម្ពោធិ៍គ្រប់ទាំង៣០បរិច្ឆេទ ឬ៣០កណ្ឌ។ ស្ថិតក្នុងបរិបទនេះគំនូររឿងមារព័ន្ធជាកណ្ឌជិតចុងបញ្ចប់ ហើយក៏កម្រមានគំនូរដែលបរិយាយអំពីរឿងនេះ ប៉ុន្តែក្នុងប្រព័ន្ធជំនឿបែបសៃយសាស្ត្រខ្មែរដែលចាស់ទុំអ្នករៀនរបៀនសឹងតែស្គាល់គ្រប់គ្នាគឺព្រះអហន្តមួយអង្គព្រះនាម ឧបគតត្ថេរ ដែលបានចង់មារជាប់នឹងគម្រង់ស្បែកឆ្កែជាប់នឹងភ្នំ។ លុះចំណេរក្រោយមកគេហៅថារឿងឧបគតចងមារ។ ដំណើររឿងត្រង់នេះខ្មែរបានបង្កើតជាមន្តចងព័ទ្ធអមនុស្សការពារខ្លួនឈ្មោះថា ចំណងព្រះឧបគត។ មានដំណើររឿងដូចខាងក្រោម៖

## ២- មារព័ន្ធបរិច្ឆេទ កណ្ឌទី២៩ (សេចក្តីសង្ខេបរឿងព្រះឧបគតចងមារ)

នៅក្នុងគម្ពីរបឋមសម្ពោធិ៍ចាប់ពីការចែកព្រះបរមសារីរិកធាតុ រហូតមកដល់ការបញ្ចុះព្រះបរមធាតុនៅតាមនគរទាំង៨ដែលបានចំណែកព្រះធាតុពីទោណព្រាហ្មណ៍ហៅថា **ធាតុនិធាន** ។ កណ្ឌនេះមានសេចក្តីរៀបរាប់យ៉ាងពិស្តារអំពីរតនៈដែលត្រូវបញ្ចុះជាមួយព្រះធាតុ របៀបបញ្ចុះព្រះធាតុ ជាពិសេសសេចក្តីជ្រះថ្លារបស់ព្រះមហាក្សត្រព្រះនាម ធម្មាសោក ជាស្តេចធំសោយរាជ្យនៅបាត្តលីបុត្តមហានគរដែលបានស្តាប់ឱវាទនិគ្រោធសាមណេរមានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានសាងវិហារ៨៤០០០ ព្រះចេតិយ៨៤០០០ ទ្រង់ចង់បានព្រះបរមធាតុមកបញ្ចុះក្នុងព្រះចេតិយទាំង៨៤០០០ទុកជាទីសក្ការៈបូជាដល់មនុស្សទូទៅ ទើបទៅអារធនាព្រះសង្ឃប្រជុំគ្នារើរកព្រះបរមធាតុនៅតាមព្រះចេតិយដែលស្តេចបុរាណទាំង៨នគរធ្លាប់បញ្ចុះ។ លុះសម្រេចតាមព្រះទ័យហើយទ្រង់ ក៏អញ្ជើញព្រះបរមធាតុដាក់ក្នុងមហាចេតិយជាទីបូជាហើយក៏ប្រារព្ធបុណ្យធ្វើពិធីឆ្លងព្រះចេតិយទាំង៨៤០០០នោះ[២]។ ព្រះសង្ឃក៏បានទៅនិមន្តព្រះឧបគតដែលលោកនិម្មិតប្រាសាទកែវនៅផ្ទៃសមុទ្រគង់អាស្រ័យនៅទីនោះ លោកជាព្រះថេរៈដែលសម្តេចព្រះមហាមុនីត្រាស់ទំនាយទុកក្នុងសាសនាកន្លងបាន២១៨ឆ្នាំមានតែព្រះឧបគតត្ថេរមួយអង្គដែលអាចទប់ទល់នឹងមារាធិរាជឱ្យបាក់បបខ្ចបខ្ចាចអស់ពុតត្បុតកំណាចហើយនឹងប្រាថ្នាពុទ្ធភូមិទៅអានាគត។ ព្រះ

[២] សាស្ត្រាបឋមសម្ពោធិ លេខកូដ F.E.M.C.a117

សង្ឃក៏ដាក់ទណ្ឌកម្មដល់ឧបគុត្តត្រូវឱ្យមកការពារមារាធិរាជ កុំឱ្យមានអន្តរាយដល់បុណ្យឆ្លងចេតិយ៨៤០០០ និងព្រះស្តូបក្នុងព្រះនគរអស់៧ឆ្នាំ៧ខែ៧ថ្ងៃ។

កាលព្រះបាទធម្មាសោកសម្ដេចឱ្យគ្រប់៧ឆ្នាំ៧ខែ៧ថ្ងៃក្នុងនោះមានខត្តិវង្ស មន្ត្រី សេដ្ឋី នៅព្រាហ្មណ៍ទៅដោយទ្រង់ប្រដាប់សម្រាប់ព្រះអង្គ ទាំងព្រះសង្ឃ នាំគ្នាមកថ្វាយបង្គំបូជាមហាចេតិយបូជាប្រទីប ធូប ទៀន បំភ្លឺរន្ទាលព្រោងព្រាយជាអនេកមានទាំងរបាំ រាំច្រៀង ប្រគុំដេញ។ គ្រានោះមារាធិរាជមានចិត្តកាលបានដឹងថាព្រះបាទធម្មាសោករាជ ព្រះអង្គធ្វើកុសលឡើងធំមិនមាននរណាប្រៀបបាន ទើបចុះមកធ្វើជាភ្លៀង ព្យុះ ខ្យល់មកពីចម្ងាយ ប៉ុន្តែដោយកម្លាំងរិទ្ធិរបស់ព្រះឧបគុតបានបក់យកទៅបាត់អស់។ មារាធិរាជបណ្ដាលឱ្យងងឹតអន្ធការសព្វទិសហើយប្រែខ្លួនជាគោធំបោលទៅដល់ប្រទីបឱ្យរលត់អស់ព្រះមហាថេរក៏និម្មិតជារូបខ្លាធំដេញខាំគោ គោភិតភ័យក៏ប្រែទៅជានាគក្បាល៧បោលទៅខាំខ្លាធំ ព្រះឧបគុតក៏ប្រែជាស្ដេចគ្រុឌទៅចាបក្បាលនាគអូសទៅអូសមក ស្ដេចនាគរាជក៏ត្រឡប់ទៅជាយក្ខកាន់ដំបងប៉ុនដើមត្នោតក្រវីក្រវាត់ចូលមករកស្ដេចគ្រុឌ ឯគ្រុឌក៏ប្រែក្រឡាត្រឡប់ជាយក្ខកាន់ដំបងពីរឆេះជាអណ្ដាតភ្លើងដេញវាយក្បាលយក្ខមារបរាជ័យ មារាធិរាជក៏តូចចិត្តថាយើងនិម្មិតជារូបផ្សេង ព្រះឧបគុតក៏និម្មិតបានគ្រប់ប្រការអាត្មាថានឹងចាញ់ព្រះថេរសម្ដែងជារូបរាមាធិរាជឱ្យអស់រិទ្ធិអស់គំនិតនឹងកែខៃ ព្រះមហាថេរនិម្មិតជារូបឆ្កែស្អុយមានក្លិនអាសោចគួរឱ្យខ្ពើមពន់ប្រមាណហើយយកមកចងកមារាធិរាជផ្ទប់នឹងក្អំ រួចអធិដ្ឋានមិនឱ្យ មនុស្សក្ដី ទេវតាក្ដី ព្រហ្មក្ដី ស្រាយបានឡើយ។ ឯមារាធិរាជកាលស្អុយគម្រង់ស្បែកឆ្កែជាប់នឹងកអស់រិទ្ធិអស់តេជះ អស់ប្រាជ្ញាស្រាយពុំរួចខ្មាសក្នុងចិត្តដល់មនុស្សទេវតាទើបឡើងទៅចតុម្មហារាជការ ហោះទៅរកព្រះឥន្ទ្រ ហោះទៅទេវតា ហោះទៅរកព្រះព្រហ្មឱ្យជួយស្រាយសំអុយឆ្កែក៏ស្រាយមិនបាន ទើបប្រាប់មារាធិរាជឱ្យលោកទើបអាចស្រាយបាន។

មារាធិរាជបានហើយក៏អង្វរព្រះឧបគុតឱ្យស្រាយ ទើបព្រះថេរឱ្យមារាធិរាជទៅកាន់ក្អំមួយក៏ស្រាយសំអុយឆ្កែនោះចេញ រួចយកខ្សែវត្តពន្ធមកចងមារាផ្អោបជាប់នឹងក្អំអស់៧ឆ្នាំ៧ខែ៧ថ្ងៃរហូតដល់ធ្វើពិធីឆ្លងព្រះចេតិយទើបស្រាយចេញ។ មារាធិរាជក៏មានសេចក្ដីទោមនស្សធាក់កំពូលភ្នំទៅវិញទៅមកហើយក៏គិតដល់ព្រះសាសនាប្រាថ្នាព្រះពោធិញាណក្នុងអនាគតកាលខាងមុខ។ ក្រោយមកព្រះឧបគុតស្រាយចំណង ហើយផ្ដាំទៅមារាធិរាជឱ្យលះបង់នៅចិត្តបាបកុំគប្បីធ្វើអំពើបាប។

អត្ថបទដោយៈ រឹម ទិត្យបញ្ញា

ម្យ៉ាងទៀតកន្លែងណាដែលមានកម្មពិធីបុណ្យចូលមារាអិរាជកុំចូលមកធារតៅធ្វើអន្តរាយ ហើយអាចសម្គាល់ទីនោះដោយមានទង់នោះនឹងមានព្រះឧបគត[៣](រូបលេខ១)។

## ៣- គំនូរមារព័ន្ធ

ដោយសារតែមានការនិយមស្តាប់គម្ពីរបឋមសម្ពោធិ៍ក្នុងសង្គមខ្មែរ(ជាគម្ពីរសម្រាប់ទេសន៍ រូបលេខ១)បានបង្កើតជាសិល្បៈគំនូរយ៉ាងវិចិត្រតាមបណ្តាលវត្តអារាមមួយចំនួន ព្រោះកណ្ឌនេះហាក់ដូចជាមិនបានផ្សាយទូលំទូលាយ ទើបគំនូរក្នុងកណ្ឌនេះពុំសូវឃើញអ្នកសិល្បៈ(ជាងគំនូរ) លើកមកបង្ហាញ។ ខាងក្រោមនេះជាគំនូរតាមបណ្តាលវត្តចាប់តាំងពីទ.វ.៤០មកបច្ចុប្បន្ន៖



រូបលេខ១ ព្រះបឋមសម្ពោធិ ជាតុនិធាន បរិច្ឆេទទី២៨ ប្រភព៖ F.E.M.

### ក.គំនូរវត្តប្រាសាទបាគង

គំនូរមារព័ន្ធ៍គេគូរនៅក្នុងព្រះវិហារពីខាងក្រោយបល្ល័ង្កព្រះជីវ៍ ដែលផ្ទៃគំនូរបានបរិយាយជូនល្មមអាចយល់ដំណើររឿងបាន(រូបលេខ២, ៣)។



រូបលេខ១ កាលព្រះអុប្បគតចាប់មារចងនឹងក្អែ មារចាញ់បរមីព្រះអុប្បគត

[៣] សាស្ត្រាបឋមសម្ពោធិ លេខកូដF.E.M.C.a117

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



រូបលេខ២២ ជាឈុតដែលមារនិមិត្តខ្លួនបង្កជាអន្តរាយយាយីដល់អ្នកស្រុក និងបំផ្លាញបុណ្យឆ្លងរបស់ព្រះបាទធម្មាសោក



រូបលេខ២៣ជាឈុតព្រះឧបគតត្តេរមារនិមិត្តខ្លួនផ្ចាញ់មារដោយឧបាយផ្សេងៗរួចក៏ចងមាននឹងវត្តពន្ធជាប់នឹងភ្នំ។ នៅត្រង់ឈុតនេះគឺជាប្រធានរឿងនៃកណ្ឌមារព័ន្ធ ដែលខ្មែរនិយមហៅថា**ព្រះឧបគតចងមារ**

### ***ខ.គំនូរវត្តពិសីវរាពម***

*វត្តពិសីស្ថិតនៅក្នុងខេត្តព្រះត្រពាំង(កម្ពុជាក្រោម)មានអាយុកាលជាង៣០០ឆ្នាំ។ គំនូរមារព័ន្ធគេគូរនៅលើជញ្ជាំងខាងកើត ផ្នែកខាងក្រៅព្រះវិហារ ផ្ទៃគំនូរបានបរិយាយអំពីបុណ្យឆ្លងចេតិយរបស់ស្តេចធម្មាសោក និងព្រះឧបគតចងមារ(រូបលេខ២៤)។*

*អត្ថបទដោយៈ រឹម ទិត្យបញ្ញា*



រូបលេខ២៨ជាឈុតព្រះបាទធម្មាសោកកំពុងធ្វើបុណ្យឆ្លងចេតិយ មារមកផ្ចាញ់ផ្ចាល់ក្រោយពីចុះចាញ់រិទ្ធីព្រះឧបគតត្ថេរ មារនិមិត្តខ្លួនជាព្រះពុទ្ធតាមបំណងរបស់ព្រះឧបគត ហើយព្រះឧបគតត្ថេរចាប់មារចងភ្ជាប់នឹងភ្នំ។

**គ.គំនូរវត្តចុងបឹងក្នុង**

គំនូរមារព័ន្ធ័នៅវត្តចុងបឹងក្នុងខេត្តកំពង់ចាម គេគូរនៅលើជញ្ជាំងជ្រុងឦសានផ្នែកខាងកក្នុងព្រះវិហារជាប្រភេទគំនូរទំនើបគូរនៅឆ្នាំ២០១៥ក្នុងគម្ពីរអនាគតទសពុទ្ធវង្ស។ ផ្ទៃគំនូរបង្ហាញអំពីសកម្មភាពព្រះឧបគតចងមារ(រូបលេខ២៥)។



រូបលេខ២៥ មារចុះចាញ់រិទ្ធីព្រះឧបគតត្ថេរ ត្រូវព្រះឧបគតត្ថេរចាប់មារចងភ្ជាប់នឹងភ្នំ។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

### ឃ.គំនូរវត្តស្វាយពក

វត្តស្វាយពកស្ថិតនៅក្នុងខេត្តព្រះត្រពាំង(កម្ពុជាក្រោម) គេគូរមារព័ន្ធនៅលើជញ្ជាំងជ្រុងឦសានផ្នែកខាងកក្នុងព្រះវិហារជាប្រភេទគំនូរទំនើបគូរនៅឆ្នាំ២០១៥។ គំនូរមារព័ន្ធគេគូរនៅលើជញ្ជាំងខាងកើតផ្នែកខាងក្រៅព្រះវិហារ ផ្ទៃគំនូរបានបរិយាយអំពីបុណ្យឆ្លងចេតិយរបស់ស្តេចធម្មាសោក និងព្រះឧបគតចងមារ(រូបលេខ២៦)។




រូបលេខ២៦ ព្រះបាទធម្មាសោកបានស្អាងចេតិយរួចរាល់គិតបម្រុងនឹងធ្វើបុណ្យឆ្លង មារក៏បានមកផ្ចាញ់ផ្ចាល់។ ក្រោយពីចុះចាញ់រិទ្ធិព្រះឧបគតត្ថេរ ទើបព្រះឧបគតត្ថេរចាប់មារចងភ្ជាប់នឹងភ្នំ។

### ង.គំនូរវត្តរកាកណ្តាល

វត្តរកាកណ្តាលគំនូរមារព័ន្ធគេគូរនៅក្នុងព្រះវិហារលើហប់ខ្យល់។ គំនូរត្រូវលុបដោយសំណឹកធម្មជាតិហើយមានស្នាកស្នាមទឹកថ្នាំគំនូរទាំងសងខាងដូចគ្នា ប៉ុន្តែយើងអាចកំណត់អត្តសញ្ញាណជាគំនូរមារព័ន្ធបានដោយសារសំណេរសេសសល់នៅលើហប់ខ្យល់ ជួនល្មមអាចយល់ដំណើររឿងបាន(រូបលេខ២៧, ៨, ៩)។

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



*រូបលេខ៧៖ [....]ព្រះ[....]វិក្កន្ទថេរតិងដំម្នឹង[....]ម្នារាពធិរាជចុះមក[....]ឱ្យ[....]នៃ[....]ដាឱនព្រះបាទ ព្រះធម្ម/ សាបទានំម ពុំឱ្យចូលបានទេព្វស្តេ[ច]ព្រះ។(ប្រភពរូប៖ អ៊ាម វិសាល)*



*រូបលេខ៨៖[....]ហេ្យបិត[....]ឱ្យពរកើត[....]កន្ត្រៃស្រាប្ញុំរតទោះជ្រែក[....]ឡើយហៃកាលមារាធិរាជ្ឋាមានះឡោឱ្យព្រះចិត្តលោកបាទព្រះឥន្ទស្រាស្បែកន្ត្រៃស្រាយឡេញុំរចៗ(ប្រភពរូប៖ អ៊ាម វិសាល)*



*រូបលេខ៨៖[....]ព្រះ[ម្នារា ] ធិរាជឡោរឱ្យព្រះព្រំម្មស្រាយព្យុំស្រាយទ្វាលតែទោរឯព្រះឧប្បគុត លោកស្រាយឱ្យស្រាយហើ[....]និងវត្តពន្ធតើកយកឡោរចងនិង[....]ម្នារឡោរប្រណិព្យព្រះឧប្បគុតថ្ងៃ សូមចុះចាញ់. [....]។ (ប្រភពរូប៖ អ៊ាម វិសាល)*

សរុបមកគំនូរមារព័ន្ធ ឬគំនូររឿងព្រះឧបគតចងមារយើងឃើញថាដំណើររឿងដែលស្តែងឡើងខុសៗ(ខ្វះខ្វី ខ្វះវែង) ទៅតាមការនិយមតាំងបុរាណ។ គំនូរនេះអាចទទួលឥទ្ធិពលអំពីរឿងនិទានក្នុងគម្ពីរបឋមសម្ពោធិ៍ រហូតកើតជារឿងព្រេងខ្មែរ បង្កើតបានជាការប្រតិបត្តិ ទំនៀមទម្លាប់ក្នុងសង្គមនៅពេលប្រារព្ធបុណ្យឆ្លងកុដិ សាលា ព្រះវិហារ បង្គន់ ទង់ សាស្រ្តា។ល។ មិនថាក្នុងវត្តអារាម ភូមិស្រុក និគមជនបទ ចុងកាត់មាត់ញកសុទ្ធតែមានលើកទង់ជាសញ្ញាពិធីដើម្បីការពារអន្តរាយពីពួកអមនុស្សកាចៗ។ ទោះបីទង់គេប្រើក្នុងន័យជោគជ័យ ឬចុះចាញ់ តែក៏អាចប្រើក្នុងទិដ្ឋភាពន័យជាសញ្ញាការពារអន្តរាយ បើយោងតាមសេចក្តីនិទានក្នុងគម្ពីរបឋមសម្ពោធិ៍។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

# ឯកសារពិគ្រោះ

គង់ ឈួយ

១៩៦៥, ព្រះមាល័យទេសនា, បាត់ដំបង

គឹម អាន

១៩៥៧, រឿងព្រះបាទធម្មាសោក, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

Internet Archive

មហាលេយ្យទិព្វថេរ (ក-កះ, ខ-ខិ) : Free Borrow & Streaming : Internet Archive

Khmer Manuscript Heritage

BUDA - Buddhist Digital Archives (bdrc.io)

អត្ថបទដោយៈ រឹម ទិត្យបញ្ញា